ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ចំនួន ២៥នាក់ និងមិនមានករណីជាសះស្បើយ ព្រមទាំងមានការរកឃើញវីរុសកូវីដ-១៩ បម្លែងថ្មីលើអ្នកជំងឺ ០៣នាក់
## នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ ៖

**១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖** គិតត្រឹមម៉ោង ០៧:០០នាទីព្រឹក នៃថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ មានដូចតារាងខាងក្រោមនេះ ៖

| ល.រ. | បរិយាយ | សរុប (នាក់) | ស្រី (នាក់) | ប្រុស (នាក់) | ផ្សេងៗ |
|---|---|---|---|---|---|
| ១. | **អ្នកមានវីរុសកូវីដ-១៩ ៖** | | | | |
| | ១.១. អ្នកដំណើរចូលមកកម្ពុជា និងអ្នកឆ្លងបន្តនៅក្នុងប្រទេស | ៤០៤ | ១០៩ | ២៩៥ | អ្នកឆ្លងថ្មី៖ **០២នាក់** |
| | ១.២. ពលករធ្វើដំណើរមកពីប្រទេសថៃ | ៩០ | ៦៩ | ២១ | អ្នកឆ្លងថ្មី៖ ០នាក់ |
| | ១.៣. ព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ | ៩៩ | ៥៣ | ៤៦ | អ្នកឆ្លងថ្មី៖ **២៣នាក់** |
| | **សរុបអ្នកមានវីរុសកូវីដ-១៩** | **៥៩៣** | **២៣១** | **៣៦២** | អ្នកឆ្លងថ្មី៖ **២៥នាក់** |
| ២. | **អ្នកព្យាបាលជាសះស្បើយ ៖** | | | | |
| | ២.១. អ្នកដំណើរចូលមកកម្ពុជា និងអ្នកឆ្លងបន្តនៅក្នុងប្រទេស | ៣៨៧ | ១០០ | ២៨៧ | អ្នកជាសះស្បើយថ្មី៖០នាក់ |
| | ២.២. ពលករធ្វើដំណើរមកពីប្រទេសថៃ | ៨៨ | ៦៨ | ២០ | អ្នកជាសះស្បើយថ្មី៖០នាក់ |
| | **សរុបអ្នកព្យាបាលជាសះស្បើយ** | **៤៧៥** | **១៦៨** | **៣០៧** | អ្នកជាសះស្បើយថ្មី៖០នាក់ |
| ៣. | **អ្នកកំពុងសម្រាកព្យាបាល ៖** | | | | ក្រសួងនឹងធ្វើការជូនដំណឹងបន្តទៀតនៅពេលដែលទទួលបានរបាយការណ៍សម្រាកព្យាបាលបន្ថែម ០២នាក់ទៀត (បើបូកបញ្ចូលទៅក្នុងចំនួនសរុប គឺ ១១៨នាក់ កំពុងសម្រាកព្យាបាល) |
| | ៣.១មជ្ឈមណ្ឌលជាតិកំចាត់រោគរបេងនិងហង់សិន | ៤៣ | ២៤ | ១៩ | |
| | ៣.២. មន្ទីរពេទ្យបង្អែក ខេត្តប៉ៃលិន | ០១ | ០១ | ០ | |
| | ៣.៣.មន្ទីរពេទ្យបង្អែក ខេត្តបន្ទាយមានជ័យ | ០១ | ០ | ០១ | |
| | ៣.៤. មន្ទីរពេទ្យបង្អែក ខេត្តបាត់ដំបង | ០ | ០ | ០ | |
| | ៣.៥.មន្ទីរពេទ្យបង្អែក ខេត្តឧត្តរមានជ័យ | ០ | ០ | ០ | |
| | ៣.៦.មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | ៤៤ | ២១ | ២៣ | |
| | ៣.៧. មណ្ឌលសុខភាពចាក់អង្រែ | ២៥ | ១៦ | ០៩ | |
| | ៣.៨.សាលារក្សាសន្តិភាពពហុសាស្ត្រកំពង់ស្ពឺ | ០២ | | ០២ | |
| | **សរុបអ្នកកំពុងសម្រាកព្យាបាល** | **១១៦** | **៦២** | **៥៤** | |

**សូមកត់សម្គាល់ថា៖ ក្រសួងសូមធ្វើការកែតម្រូវមានដូចខាងក្រោម៖**

-មានអ្នកជំងឺជាស្ត្រីចំនួន ០១នាក់ បានប្តូរពីមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន មក សម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែ។

**២. ព័ត៌មានប្រចាំថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១**

**ក. ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖ សរុបចំនួន ២៥នាក់**

**ក.១. ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖ ចំនួន ២៣នាក់ ដែលជាអ្នកពាក់ព័ន្ធទៅព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ**

- ស្ត្រីជនជាតិចិន អាយុ ៣៩ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ២៥ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិខ្មែរ អាយុ ២០ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំចុងដូង ស្រុកបារាយណ៍ ខេត្តកំពង់ធំ។
- បុរសជនជាតិចិន អាយុ ៣១ឆ្នាំ មានអាសយដ្ឋានស្នាក់នៅសណ្ឋាគារមួយក្នុងរាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ៣២ឆ្នាំ មានអាសយដ្ឋានស្នាក់នៅសណ្ឋាគារមួយក្នុងរាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ៤៨ឆ្នាំ មានអាសយដ្ឋានស្នាក់នៅសណ្ឋាគារមួយក្នុងរាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ២៦ឆ្នាំ មានអាសយដ្ឋានស្នាក់នៅសណ្ឋាគារមួយក្នុងរាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ២៥ឆ្នាំ មានអាសយដ្ឋានស្នាក់នៅរាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ២៩ឆ្នាំ មានអាសយដ្ឋានស្នាក់នៅរាជធានីភ្នំពេញ។
- បុរសជនជាតិចិនអាយុ ៣៦ឆ្នាំ មានអាសយដ្ឋានស្នាក់នៅសង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ៤៨ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ កោះពេជ្រ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ៤១ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ កោះពេជ្រ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ៣៦ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិវៀតណាម អាយុ ២៨ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ២៥ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ២៨ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ២០ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ២៣ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ២៣ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ៣០ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ខណ្ឌចំការមន រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ២៦ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។

**សម្គាល់៖** បច្ចុប្បន្នអ្នកជំងឺ ២១នាក់ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ។

- ស្ត្រីជនជាតិខ្មែរអាយុ ៥២ឆ្នាំ មានអាសយដ្ឋានស្នាក់នៅខណ្ឌឫស្សីកែវរាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ២៣ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។

**សម្គាល់៖** អ្នកជំងឺខាងលើនេះ: ០១នាក់ មិនអាចទាក់ទងបាន និង ០១នាក់ទៀត មិនព្រមមកសម្រាកព្យាបាលនៅមន្ទីរពេទ្យ ដោយសម្អាងគាត់មានកូនតូចនៅជាមួយ ដែលអាជ្ញាធរមានសមត្ថកិច្ច និងមន្ត្រីសុខាភិបាល កំពុងតែសម្របសម្រួលនៅថ្ងៃនេះ។

**ក.២. ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖ ចំនួន ០២នាក់ ដែលជាអ្នកដំណើរចូលមកកម្ពុជា (មិនមែនជាពលករធ្វើដំណើរមកពីប្រទេសថៃ)**

- បុរសជនជាតិខ្មែរ អាយុ ៥០ឆ្នាំ បំរើការនៅអង្គការសហប្រជាជាតិ (កងទ័ពមួកខៀវUN) មានអាសយដ្ឋានស្នាក់នៅខេត្តកំពង់ស្ពឺ ជាអ្នកធ្វើដំណើរមកពីប្រទេសអាហ្វ្រិក បន្តជើងហោះហើរនៅប្រទេសឥណ្ឌា មកដល់កម្ពុជានៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២១។ លទ្ធផលធ្វើតេស្តវត្តសំណាករបស់បុរសរូបនេះផ្តល់ដោយវិទ្យាស្ថានជាតិសុខភាពសាធារណៈ នៃក្រសួងសុខាភិបាល គឺ វិជ្ជមានវីរុសកូវីដ-១៩ ហើយបច្ចុប្បន្នអ្នកជំងឺត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅសាលារក្សាសន្តិភាពពហុសាស្ត្រកំពង់ស្ពឺ ។

- បុរសជនជាតិខ្មែរ អាយុ ៣៥ឆ្នាំ បំរើការនៅអង្គការសហប្រជាជាតិ (កងទ័ពមួកខៀវUN) មានអាសយដ្ឋានស្នាក់នៅខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ជាអ្នកធ្វើដំណើរមកពីប្រទេសអាហ្វ្រិក បន្តជើងហោះហើរនៅប្រទេសឥណ្ឌា មកដល់កម្ពុជានៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២១។ លទ្ធផលធ្វើតេស្តវត្តសំណាករបស់បុរសរូបនេះ ផ្តល់ដោយវិទ្យាស្ថានជាតិសុខភាពសាធារណៈ នៃក្រសួងសុខាភិបាល គឺ វិជ្ជមានវីរុសកូវីដ-១៩ ហើយបច្ចុប្បន្នអ្នកជំងឺត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅ សាលារក្សាសន្តិភាពពហុសាស្ត្រកំពង់ស្ពឺ ។

**សូមកត់សម្គាល់ថា៖** អ្នកដំណើរតាមយន្តហោះជាមួយអ្នកជំងឺខាងលើ សរុបមានចំនួន ១១៩នាក់ ដែលនៅក្នុងចំនួននេះមាន បុរសខាងលើនេះផងដែរ។ រីឯ អ្នកដំណើរចំនួន ១១៧នាក់ ដែលមានលទ្ធផល តេស្តអវិជ្ជមានវីរុសកូវីដ-១៩ នោះត្រូវបានដាក់ឲ្យធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ នៅសាលារក្សាសន្តិភាពពហុសាស្ត្រកំពង់ស្ពឺ ចំនួន ១១៧នាក់។

**ខ. មិនមានករណីជាសះស្បើយ ៖** នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១

**៣.ការរកឃើញវីរុសកូវីដ-១៩ បែបបំប្លែងថ្មី ចំនួន ០៣ករណី នៅក្នុងព្រះរាជាណាចក្រកម្ពុជា**

យោងតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណៈជនទាំងអស់ឱ្យបានជ្រាបថា ស្ថានភាពនៃការចម្លងវីរុសកូវីដ-១៩ បច្ចុប្បន្ន និងវីរុសកូវីដ-១៩ បំប្លែងថ្មី កំពុងតែរាលដាលយ៉ាងសកម្ម នៅបណ្តាប្រទេសនៅលើសកលលោក និងនៅក្នុងតំបន់។ ថ្មីៗនេះ ប្រទេសកម្ពុជា បានរកឃើញករណីឆ្លងវីរុសកូវីដ-១៩ ដែល **សម្តេចតេជោ** បានប្រសិទ្ធិនាមថាជា "ព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ" ដែលកំណើននៃការឆ្លងវីរុសកូវីដ-១៩ នៅតែបន្តកើនឡើងនៅឡើយ។ បើទោះបីជាប្រទេសកម្ពុជា មិនទាន់មានករណីស្លាប់ដោយសារជំងឺកូវីដ-១៩ ក៏ដោយ ក៏ហានិភ័យនៃការចម្លងវីរុសដ៏កាចសាហាវនេះនៅតែមានខ្ពស់ ហើយស្ថានភាពបច្ចុប្បន្ន គឺមានសភាពកាន់តែធ្ងន់ធ្ងរជាង និងស្មុគស្មាញជាង ព្រឹត្តិការណ៍សហគមន៍ ២៨វិច្ឆិកា កន្លងទៅ ជាពិសេស គឺការចម្លងប្រភេទវីរុសបំប្លែងថ្មី ដែលការចម្លងរបស់វា មានសភាពកាចសាហាវ និងលឿនជាងធម្មតា។

ជាក់ស្តែង នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង ០៦:៣០នាទីល្ងាច លទ្ធផលវិភាគពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា បានបញ្ជាក់នូវការវិភាគរកឃើញ អ្នកជំងឺ ០៣នាក់ មានឆ្លងវីរុសកូវីដ-១៩ បម្លែងថ្មី (ប្រភេទ SARS-CoV-2 UK Variant 20I/501Y.V1, B.1.1.7) ។ បុគ្គលទាំងបីនាក់នេះ ម្នាក់មានអាសយដ្ឋាននៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ និងពីរនាក់ទៀតជាអ្នកនៅក្លឹបកំសាន្ត N8។ ករណីឆ្លងលឿនបែបនេះ នឹងមានលទ្ធភាពអាចបន្តឆ្លងនៅក្នុងសហគមន៍ប្រសិនបើប្រជាពលរដ្ឋយើង មិនបានយកចិត្តទុកដាក់បន្តអនុវត្តន៍វិធានការណ៍សុខាភិបាល ដែលក្រសួងក៏ធ្លាប់បានចេញសេចក្តីណែនាំក្រើនរំលឹកអំពាវនាវជារឿយៗដែរ។

ដូច្នេះ ក្រសួងសុខាភិបាល សូមធ្វើការក្រើនរំលឹក និងអំពាវនាវសារជាថ្មី ជូនដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ បន្តចូលរួមទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩នៅក្នុងសហគមន៍យើង ដោយទាំងអស់គ្នា ត្រូវបន្តអនុវត្តន៍តាមការណែនាំជំ

ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានថ្លែងនៅក្នុងសន្និសីទសារព័ត៌មាននាព្រឹកថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ និងការណែនាំរបស់ក្រសួងសុខាភិបាល ដែលមានដូចខាងក្រោមនេះ។ សូមបងប្អូនប្រជាពលរដ្ឋទាំងអស់នៅទូទាំងប្រទេស និងជាពិសេសអ្នករស់នៅក្នុងរាជធានីភ្នំពេញ និងខេត្តកណ្តាល ត្រូវប្រកាន់យកនូវការប្រុងប្រយ័ត្នខ្លួនជាប់ជានិច្ច គ្រប់គ្រងក្រុមគ្រួសារឱ្យបានល្អ សហការសាមគ្គីភាពគ្នា ជួយគ្នាទៅវិញទៅមក ចូលរួមអនុវត្តន៍ដោយម៉ឺងម៉ាត់នូវវិធានការសុខាភិបាល ដែលមានដូចតទៅ៖

**ក. បុគ្គលដែលធ្លាប់បានចេញចូលទីតាំងខាងលើ និងទីតាំងផ្សេងៗទៀតដែលក្រុមរុករកបានទៅដល់** ពីថ្ងៃទី០៦ ដល់ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ ឬបុគ្គលពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬដឹងថាខ្លួនជាអ្នកប៉ះពាល់ជាមួយអ្នកមានវីរុសកូវីដ-១៩ ត្រូវមានភាពស្មោះត្រង់ មិនលាក់លៀម និងស្ម័គ្រចិត្តមកធ្វើតេស្តរកមេរោគកូវីដ-១៩ នៅរៀងរាល់ម៉ោងធ្វើការ សូមអញ្ជើញមកធ្វើតេស្ត យកវត្ថុសំណាកដើម្បីវិភាគរកវីរុសកូវីដ-១៩ នៅមណ្ឌលសុខភាពចាក់អង្រែនៃរាជធានីភ្នំពេញសម្រាប់ប្រជាជនទូទៅ ការយកវត្ថុសំណាកធ្វើនៅមជ្ឈមណ្ឌលកោះពេជ្រសម្រាប់ជនជាតិចិន និង ធ្វើនៅស្តាតអូឡាំពិចសម្រាប់អ្នករត់ម៉ូតូកង់បី ឬផាស់អាប់ និងអ្នករត់តាក់ស៊ី ដែលធ្លាប់ដឹកភ្ញៀវនៅតាម ២៣ទីតាំងខាងលើ ហើយត្រូវដាក់ខ្លួននៅដាច់ដោយឡែកពីក្រុមគ្រួសារ ព្រមទាំងធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃនៅតាមផ្ទះរៀងៗខ្លួន ដោយធ្វើការតាមដានសុខភាពជារៀងរាល់ថ្ងៃ។ ប្រសិនបើមានអាការៈមិនស្រួលខ្លួន ដូចជាមានឡើង កំដៅខ្លួន ក្អក ផ្តាសាយ ឈឺបំពង់ក ឬពិបាកដកដង្ហើមជាដើម សូមហៅទៅលេខទូរស័ព្ទទាន់ហេតុការណ៍ ១១៥ ឬលេខទូរស័ព្ទដែលមានជូននៅខាងក្រោមនេះស្រាប់ ដើម្បីជួយអន្តរាគមន៍សុខភាពបានទាន់ពេលវេលា។

**ខ. ត្រូវចូលរួមធ្វើចត្តាឡីស័ក**ឱ្យបានត្រឹមត្រូវ និងគ្រប់ចំនួន ១៤ថ្ងៃ តាមការណែនាំរបស់ក្រសួងសុខាភិបាលសម្រាប់អ្នកដែលសង្ស័យ ឬដែលបានប៉ះពាល់ដោយផ្ទាល់ ឬប្រយោលជាមួយនឹងបុគ្គលដែលបានរកឃើញថាមានវិជ្ជមានវីរុសកូវីដ-១៩។ ការធ្វើចត្តាឡីស័កនេះ ត្រូវធ្វើនៅតាមគេហដ្ឋានរៀងៗខ្លួន រីឯបុគ្គលដែលមិនមានលទ្ធភាពធ្វើចត្តាឡីស័កនៅផ្ទះរបស់ខ្លួន អាជ្ញាធរថ្នាក់ក្រោមជាតិ មានភារកិច្ចក្នុងការគ្រប់គ្រងតាមដានការអនុវត្ត និងចាត់ចែងទីកន្លែងសម្រាប់ការធ្វើចត្តាឡីស័កនេះ។

**គ. ត្រូវចូលរួមផ្តល់ព័ត៌មាន** ស្តីពីទំនាក់ទំនងផ្ទាល់ ឬប្រយោលរវាងបុគ្គល និងបុគ្គល ដែលមានការពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ ដោយមិនមានការលាក់លៀម ដើម្បីឈានទៅកំណត់មុខសញ្ញាសង្ស័យថាអាចមានការឆ្លងវីរុសកូវីដ-១៩ យកវត្ថុសំណាកទៅធ្វើតេស្តរកវីរុសកូវីដ-១៩ និងត្រូវដាក់បុគ្គលនោះឱ្យនៅដាច់ដោយឡែក ដើម្បីរង់ចាំលទ្ធផលពីមន្ទីរពិសោធន៍។

**ឃ. សហការផ្តល់ព័ត៌មានជាក់លាក់ ដើម្បីឱ្យសកម្មធ្វើការរុករកស្រាវជ្រាវ** រកអ្នកដែលប៉ះពាល់ផ្ទាល់ ឬប្រយោល និងយកយកវត្ថុសំណាកទៅធ្វើតេស្តរកវីរុសកូវីដ-១៩ ព្រមទាំងដាក់អ្នកវិជ្ជមានវីរុសកូវីដ-១៩ នៅដាច់ដោយឡែក និងផ្តល់ការព្យាបាលនៅក្នុងមន្ទីរពេទ្យរដ្ឋភ្លាមៗ អាចប្រព្រឹត្តទៅបានរហ័ស ចៀសវាងការអូសបន្លាយពេលវេលាយូរ ដែលអាចបង្កគ្រោះថ្នាក់សុខភាព បណ្តាលមកពីការចម្លងវីរុសដ៏កាចសាហាវនេះ ដោយយើងមិនបានដឹង និងមានហានិភ័យខ្ពស់ក្នុងការចម្លងបន្តគ្នាលឿនក្នុងទ្រង់ទ្រាយធំធេងដែលអាចបង្កស្ថានភាពរាតត្បាតអាក្រក់នៅក្នុងប្រទេសកម្ពុជា។

**ង. បើមិនចាំបាច់ សុំនៅផ្ទះ** (កុំចេញក្រៅផ្ទះ ដោយមានការប្រុងប្រយ័ត្នពីការឆ្លងបន្តគ្នានូវវីរុសកូវីដ-១៩ ជាពិសេសវីរុសកូវីដ-១៩ ដែលបម្លែងថ្មី) និងមើលការខុសត្រូវកូនចៅឱ្យបានល្អ ក្នុងពេលសកម្មភាពស្វែងរកអ្នកដែលប៉ះពាល់កំពុងតែសកម្ម។

**ច. មិនត្រូវមានការរើសអើង** ដល់អ្នកដែលរងគ្រោះឆ្លងវីរុសកូវីដ-១៩ ឬរើសអើងពូជសាសន៍ ឬរើសអើងមនុស្សតាមតំបន់ដែលមានការឆ្លងច្រើន ផ្ទុយទៅវិញ ត្រូវចេះជួយគ្នាទៅវិញទៅមក ដើម្បីរួមគ្នាបញ្ចប់នូវសភាពការណ៍ កុំឱ្យវិវត្តន៍ទៅកាន់ស្ថានភាពអាក្រក់ពេក ដែលនឹងប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិ។

**ឆ.** បុគ្គលគ្រប់រូប ចាំបាច់ត្រូវអនុវត្តន៍វិធានការ **៣ការពារ** (ពាក់ម៉ាស់ លាងដៃញឹកញាប់ និងរក្សាគម្លាតសុវត្ថិភាពបុគ្គលពីមួយម៉ែត្រកន្លះឡើង) និង **៣កុំ** (កុំទៅកន្លែងដែលមានមនុស្សកកកុញច្រើន កុំទៅកន្លែងដែលបិទជិតឈឹងមិនមានខ្យល់ចេញចូល និងប្រើម៉ាស៊ីនត្រជាក់ច្រើនពេក និងកុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា កុំឱបគ្នា នៅពេលជួបគ្នា ការធ្វើគារវកិច្ចដោយសំពះគ្នា ងក់ក្បាល ឬគ្រវីដៃ ជាដើម) គ្រប់ពេលវេលា គ្រប់កាលទេសៈ និងគ្រប់ទីកន្លែង។

## ទីតាំងពាក់ព័ន្ធព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១

| ល.រ | ទីតាំង | អាសយដ្ឋាន | | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | ផ្ទះលេខ | ផ្លូវ | សង្កាត់ | ខណ្ឌ | |
| ១ | ក្លឹប N8 | | ២១៧ កែង ២៨៦ | ទួលស្វាយព្រៃទី២ | បឹងកេងកង | បានបិទ |
| ២ | Casa By Meridian | កោះពេជ្រ | St. Harvard | ទន្លេបាសាក់ | ចំការមន | បានបិទ |
| ៣ | Le Gong Guan Hotel | ១២៦ | ១៧២ | ផ្សារថ្មីទី៣ | ដូនពេញ | បានបិទ |
| ៤ | City Comfort | អគារ២៨ | ១១៥ | បឹងព្រលឹត | ៧មករា | បានបិទ |
| ៥ | The Bridge | | ៧៨ | ទន្លេបាសាក់ | ចំការមន | បានបិទ |
| ៦ | The Point Service Apartment | ៦៣ | ២១៩ | ផ្សារដើមគ | ទួលគោក | បានបិទ |
| ៧ | Mekong Street | ៨ | ទន្លេមេគង្គ | ជ្រោយចង្វារ | ជ្រោយចង្វារ | បានបិទ |
| ៨ | Pent House Apartment | មុខ Aeon1 | សុធារស | ទន្លេបាសាក់ | ចំការមន | បានបិទ |
| ៩ | Skyline Dumex | | ១៣៨ | មិត្តភាព | ៧មករា | បានបិទ |
| ១០ | Somet Condoninium | | 236 | វាលវង់ | ៧មករា | បានបិទ |
| ១១ | Residence L Olympic | ១១៧ | ២៩២ | អូឡាំពិច | បឹងកេងកង | បានបិទ |
| ១២ | Prince Plazza Centre | | នរោត្តម | ទន្លេបាសាក់ | ចំការមន | បានបិទ |
| ១៣ | Celeste Skybar | ទល់មុខសូហ្វីតែល | សុធារស | ទន្លេបាសាក់ | ចំការមន | បានបិទ |
| ១៤ | Diamond Twin | | កោះពេជ្រ | ទន្លេបាសាក់ | ចំការមន | បានបិទ |
| ១៥ | JinZun ខារ៉ាអូខេមុខព្រលាន | | ផ្លូវសហព័ន្ធរុស្ស៊ី | កាកាប | ពោធិ៍សែនជ័យ | បានបិទ |
| ១៦ | ក្លឹប Coco សណ្ឋាគារកណ្តាលសួនច្បារ | | | ចតុមុខ | ដូនពេញ | បានបិទ |
| ១៧ | JuHao មុខហាងឆ្នេរមាស | | | ទន្លេបាសាក់ | ចំការមន | បានបិទ |
| ១៨ | ហាង The World | ក្រោយផ្សារបឹងត្របែក | | បឹងត្របែក | ចំការមន | បានបិទ |

| | | | | | | |
|---|---|---|---|---|---|---|
| ១៩ | ហាថ វ៉ែនមែនសិន | ក្រោយផ្សារបឹងត្របែកផ្លាហ្សា | | បឹងត្របែក | ចំការមន | **បានបិទ** |
| ២០ | ក្លឹប ១៦៨ អតីតនគរសំរិទ្ធិ | កែងវត្តមហាមន្ត្រី | អគារលេខ៥៦ | អូឡាំពិច | បឹងកេងកង | **បានបិទ** |
| ២១ | Love | ក្រោយអ៊ិទ្ធ | | បឹងកាំង | ដូនពេញ | **បានបិទ** |
| ២២ | វិទ្យាល័យហ៊ុនសែនភ្នំពេញថ្មី | ក្រោយវត្តសំរោងអណ្ដែត | | គោកឃ្លាង | សែនសុខ | **បានបិទ** |
| ២៣ | សាលា SIS | អគារលេខ១៨ | ៣៣៦ | ផ្សារដើមគ | ទួលគោក | **បានបិទ** |

បន្ថែមលើទីតាំងទាំង ២៣ខាងលើ យោងតាមលិខិតលេខ ១៦ អយក.សណន ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ ក៏មានការផ្អាកដំណើរការគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ជាបណ្ដោះអាសន្នរយៈពេល ០២ សប្ដាហ៍ នៅរាជធានីភ្នំពេញ និងខេត្តកណ្ដាល។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត **សម្ដេចតេជោ ទីតា** អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺឆ្លង សហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងមន្ទីរពិសោធន៍នៃមន្ទីរពេទ្យខេត្តសៀមរាប ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៨២៤ ឬ ០១២ ៨៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃអង្គារ ១២កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១